# ស័ង្ខសិល្បជ័យ

## ភាគទី១០

លុះរួចរាល់អស់ហើយ ព្រះពោធិសត្វក៏ចូលប្រឡាបន្ទំត្រាស់ហៅសុពណ៌ទេវីថា ហៃអនុជក្សត្រស្រីប្អូនស្ងួន នាងនៅពួនថ្វីកុំនាងយំសោកនឹងប្ដីឡើយ។ ចូរទៅនឹងបង ទៅនឹងនៅជាមួយនឹងម្ដាយជួបជុំត្រកូលឯស្ថានមនុស្សវិញ។ សុពណ៌ទេវីឮស្ដេចបងហៅដូច្នេះក្សត្រីភិតភ័យណាមួយនឹកអាល័យស្វាមី ណាមួយភ័យខ្លាចមិនដឹងជាយក្សឬគ្រុឌ ឬឥសីអ្វីដែលមកប្រយុទ្ធយករាជសម្បត្តិនិងរូបខ្លួនដូច្នេះ នាងគិតថាឱអញហើយ ព្រាត់មាតាបិតាហើយពេលនេះព្រាត់ស្វាមីទៀត នេះស្ដេចមកពីណាអាងតែខ្លួនមានបុណ្យឫទ្ធីមកតតាំងយកភរិយាគេដូច្នេះ ឲ្យអង្គអញជាស្រីរស់នៅប្រាស់ចាកពីប្ដី ប្រុសពាលផងប្រាកដជានិន្ទាពុំគិតក្រែងអ្វីឡើយ បើម៉្លេះទៅហើយស៊ូស្លាប់ទៅល្អជាង។

កាលនោះព្រះពោធិសត្វ បានតឿនក្សត្រីថាឲ្យឆាប់ឡើងនឹងអាលចេញដំណើរ។ សុពណ៌ទេវីឮព្រះរៀមតឿន ចិត្តមិនចង់ចេញទៅទេ ប្រាប់ថាខ្ញុំនៅរកស្មៀតសក់ដែលបិតាឲ្យ...។ រួចហើយនាងផ្ដាំទ្វារថា ចូរទ្វារចាំបណ្ដាំអញណាប្រាប់ថាអញចេញទៅទាំងទុក្ខសោកទោម្នេញពុំមានស្បើយទេ។

កាលនោះព្រះពោធិសត្វដោយរង់ចាំនិងតឿនជាច្រើនគ្រានៅតែមិនមកទ្រង់ក៏មានបន្ទូលថា "បើមិនព្រមចេញមកទេយើងនេះនឹងកាត់យកសិរសាយកទៅថ្វាយមាតុច្ឆា ហើយដើម្បីកុំឲ្យខុសនឹងរាជសវនីយ៍ទ្រង់ យើងគិតថាយើងជាបងពិត ទើបយើងឆ្លងភពមកយកនាងទៅ បើនាងមិនគិតមិនអាល័យមាតា ហើយមកអាល័យអ្នកក្រៅមិនព្រមទៅដូច្នេះ យើងនឹងទូលទ្រង់ឲ្យដឹងសព្វប្រការ..."។

សុពណ៌ទេវីកាលឮព្រះអង្គក្រោធដូច្នេះភិតភ័យខ្លាចស្លាប់ក៏ចេញមកព្រមជាមួយព្រះពោធិសត្វនាំក្សត្រីគង់លើស័ង្ខជ្រែកទឹកឡើងមក ហើយក៏បានជួបនឹងមាតា ក្សត្រីកេសរសុមន្ទាកាលទ្រង់ឃើញបុត្រមកដល់ក៏អោបបុត្រទ្រង់ព្រះកន្សែងរៀបរាប់ថា: "កូនអើយ! មាសមកដល់ហើយសព្វថ្ងៃម្ដាយវែងកើតទុក្ខឥតស្បើយ គិតដល់កូនជានិច្ច។ ហើយពេលនេះព្រះមាតុលា នៅឯបញ្ចាលនគរប្រើម្នាស់បងកូនឲ្យមករកមាតា ហើយក៏

អត្ថបទដោយ៖ មាស សុភាព

បានប្រយុទ្ធនឹងបិតាបុត្រៗ ចាញ់ឫទ្ធិក៏មរណាទៅ...”។ ចំណែកសុពណ៌ទេវី ក៏រៀបរាប់ប្រាប់មាតាវិញដែរ។ បន្ទាប់មកព្រះពោធិសត្វទ្រង់នាំមាតុច្ឆានិងប្អូនស្រីឡើងគង់លើរាជសីហ៍ដែលមានស័ង្ខនាំមុខចាកចេញពីប្រាសាទសំដៅទៅបញ្ចាលនគរ...។

យើងស្ទុះត្រឹមនេះមិននិយាយ យើងបែរង៉ាកមកមើលស្ដេចនាគវិញម្ដង ក្រោយពេលដែលព្រះពោធិសត្វចេញផុតពីរថ្ងៃបីថ្ងៃ ស្ដេចនាគក៏បានឲ្យសេនាមកមើលប្រាសាទ លុះបានដឹងថាស័ង្ខសិល្បជ័យនាំមហេសីទៅក៏សោយសោកបោកខ្លួនស្លាយមហេសី...។

យើងសូមនិយាយពីដំណើររឿងរបស់ព្រះពោធិសត្វនាំមាតុច្ឆា និងប្អូនស្រីហោះទៅដល់ឋានយក្សវនរាជជាបងកុម្ភ័ណ្ឌ។ វនរាជសួរថា: “តើទាំងបីនាក់ទៅណា?”។ កេសរសុមន្ទាប្រាប់ថា:”ទៅសួរបងឈឺនៅឯស្រុកបានក្រាបលាស្វាមីហើយ”។ វនរាជមិនបានដឹងរឿងក៏ថា: “បើដូច្នោះឡើងលើដៃយើងមក យើងជូនទៅ”។ ទាំងបីនាក់មិនក្ងួយបានជិះលើដៃវនរាជហោះមកនគរវិញ កាលនោះស្ដេចបងទាំងប្រាំមួយ ឃើញយក្សភ័យស្ទន់ស្ទោរត់ពួនគ្រប់គ្នា។ វនរាជបានបន្ទាបដៃឲ្យក្សត្រទាំងបីអង្គចុះ រួចក៏លាត្រលប់ទៅវិញ។ ព្រះពោធិសត្វទ្រង់ហៅអស់ស្ដេចបងទាំងប្រាំមួយមក ហើយណែនាំសំណេះសំណាលជាមួយមាតុច្ឆា រួចហើយនឹងយាត្រាត្រឡប់ទៅនគរវិញ។ កាលនោះស្ដេចទាំងប្រាំមួយគិតថា:”បើឲ្យវានាំមាតុច្ឆាចូលនគរ វានឹងបានគុណសម្បត្តិថ្កើងយស ចំណែកយើងនិងអប្បយស ដូច្នេះគួរតែសម្លាប់វាដើម្បីកុំឲ្យទៅបាន”។ គិតគ្នាស្រេចក៏បបួលស័ង្ខសិល្បជ័យថាទៅបេះផល្លាថ្វាយព្រះមាតុច្ឆា។ ព្រះពោធិសត្វក៏ឲ្យមាតុច្ឆាទៅចាំទីនោះ ខ្លួននឹងបងទៅដើរលេង។ លុះដល់ព្រៃឆ្ងាយបន្តិចស្ដេចបងទាំងប្រាំមួយក៏ប្រាប់ស័ង្ខសិល្បជ័យថាឲ្យទុកសរ ខ័ន និងស័ង្ខនៅមួយកន្លែងសិនចុះ។

ស័ង្ខសិល្បជ័យដោយមិនដឹងពីពុតត្បុតរបស់បងក៏ទុកតាមហើយដើរលេងតាមដងព្រៃ។ លុះទៅដល់ជ្រោះជ្រៅមួយពួកបងទាំងប្រាំមួយក៏បាននាំគ្នាច្រានស័ង្ខសិល្បជ័យទម្លាក់ជ្រោះ ព្រមទាំងបានយកថ្មសង្កត់ពីលើទៀតផង។ រួចហើយក៏ប្រញាប់មកយកព្រះខ័ន និងសរតែព្រះខ័ន និងសរក៏រលាយបាត់អស់ទៅ។ ស្ដេចពាលទាំងប្រាំមួយធ្វើជារត់ចុះពីលើភ្នំ ហើយទូលមាតុច្ឆាថា: “ស័ង្ខសិល្បជ័យដើរលេងម្នាក់ឯងពួកខ្ញុំមិនបានជាមើលក៏ធ្លាក់ជ្រោះបាត់ទៅ...”។

អត្ថបទដោយ៖ មាស សុភាព

## អត្ថបទ៖ ស័ង្ខសិល្បជ័យ

កេសរសុមន្ធា និងសុពណ៌ទេវីកាលបានស្តាប់ហើយ ភិតភ័យឥតឧបមារត់ស្រែកហៅ ស័ង្ខសិល្បជ័យគ្រប់ច្រកល្ហកតាមដងព្រៃ ប៉ុន្តែនៅតែមិនឃើញ ក្សត្រីសោយសោក រៀបរាប់ថា៖"ឱបុត្រកំព្រាកំសត់ម្តាយអើយ បុណ្យបុត្រលើសលន់ពេកកន្ទង់ខំស្កាត់ពី នាយដល់អាយតាមរកមាតាតតាំងយក្សនិងនាគបានសម្រេចហើយ ម្តេចឡើយមរណា ពេលនេះ។ សុពណ៌ទេវីសោយសោករហូតសន្ធប់បាត់ស្មារតី កេសរសុមន្ធាបានយកទឹក ភ្នែកស្រពឲ្យបានដឹងស្មារតីឡើងវិញ ហើយក៏រត់រកតាមដងស្ទឹងទៀត..."។ ស្តេចទាំង ប្រាំមួយឃើញដូច្នេះក៏ទូលលោមមាតាថា៖"ស័ង្ខសិល្បជ័យស្លាប់ហើយ សូមយាងព្រះ មាតុច្ឆាចូលនគរ..."។ កេសរសុមន្ធាស្តាប់ហើយ គ្រោធជាខ្លាំងថា៖ "កាលអញលំបាកនៅ ព្រៃជាមួយយក្សគ្មាននរណាទៅយកអញមកទេ ឥឡូវនេះចំណេះអ្វីថាមកចង់នាំអញទៅ បើចង់ ទៅតែម្នាក់ឯងទៅ"។ ស្តេចមារទាំងប្រាំមួយក៏គ្រោធហើយអូសដៃក្សត្រីទាំងពីរ ឡើងជិះសេះ កេសរសុមន្ធាខ្វាល់បន្ទូលដេរហើយទ្រង់ក៏យកពស្ត្រាដែលបានពីព្រះឥសូរ មកផ្សងនៅឆ្នេរទឹក ចំណែកសុពណ៌ទេវីក៏យកស្នៀតសក់មកផងដែរ ទាំងពីរអង្គលើក ព្រះហត្ថាផ្សងថា៖

បពិត្រទេព្តា   អ្នកផងរក្សា   សមុទ្រជលធី
យើងខ្ញុំដង្ហើយ   ផ្សងដោយបារមី   សូមជុតដូចក្តី
បំណងប្រាថ្នា។

បើមហាក្សត្រថ្លៃ   ព្រះស័ង្ខសិល្បជ័យ   អ្នកមានជន្មា
រស់រូបពុំក្ស័យ   ក្សត្រថ្លៃនៅជា   ឲ្យមានអស់ពា
ណិជ្ជអ្នកឈ្មួញឆ្ងាយ។

នៃស្បៃកាលា   ស្នៀតសក់នេះណា   យកទៅថ្វាត់ថ្វាយ
ដល់ស្រុកបងខ្ញុំ   ឧត្តមពណ្ណរាយ   កុំខាននៅអាយ
បាត់ស្វាត់ឡើងណា។

បើមហាក្សត្រថ្លៃ   វិសេសលើសក្រៃ   ពុំមានជន្មា
ក្សិណក្ស័យជីវិត   អស់ឥតអង្គា   ឲ្យទ្រព្យនេះណា
បាត់ស្វាត់នៅអាយ។

អត្ថបទដោយ៖ មាស សុភាព

លុះក្សត្រីទាំងពីរផ្សងរួច ស្ដេចពាលទាំងប្រាំមួយក៏ចាប់ដៃឡើងជិះសេះចេញទៅ...។ សូមស្ទេះត្រឹមនេះមិននិយាយ សូមនិយាយពីរាជសីហ៍កាលត្រឡប់ពីព្រៃវិញមិនឃើញស័ង្ខសិល្បជ័យភិតភ័យ ក៏បានហោះរកសព្វទិសទីពុំឃើញៗតែធ្នូសរ និងព្រះខ័នក៏ខាំពាំហោះទៅទីស្ថានមណ្ឌលរបស់មាតា។

បទុមា និងកេសរបុប្ផាកាលបើឃើញ តែធ្នូសរ និងព្រះខ័នបាត់ស័ង្ខសិល្បជ័យភិតភ័យណាស់ សួររាជសីហ៍ៗក៏រៀបរាប់តាមដំណើររឿង។ កេសរបុប្ផាខឹងណាស់ក៏បានវាយរាជសីហ៍ ហើយថា: "ហេតុអ្វីក៏មិនចេះមើលថៃប្អូន?" មាតាទាំងពីរយំសោកបោកខ្លួន ហើយក៏ហៅឲ្យរាជសីហ៍ហោះជូនទៅកន្លែងដែលបាត់ស័ង្ខសិល្បជ័យ ដោយតេជបារមីនៃព្រះពោធិសត្វបណ្ដាលឲ្យក្ដៅដល់ព្រះឥន្ទ្រ ទ្រង់បើកទិព្វចក្ខុមើលក៏ឃើញថា ព្រះពោធិសត្វធ្លាក់ក្នុងជ្រោះជ្រៅ ហើយត្រូវគេយកថ្មសន្ធប់ពីលើទៀត។ ទ្រង់ទតឃើញដូច្នេះ ព្រះឥន្ទ្រក៏ហោះទៅដល់ ក៏បើកថ្មចេញយកព្រះពោធិសត្វឡើង ហើយក៏យកទឹកទិព្វសុរាអម្រឹតមកស្រោចស្រព ធ្វើឲ្យព្រះពោធិសត្វមានពន្លឺចែងចាំងល្អលើសមុនទៀត។ រួចហើយទ្រង់ក៏លើកព្រះពោធិសត្វដាក់ដល់ទីប្រាសាទពិស្ណុ។ ព្រះពោធិសត្វពុំឃើញព្រះមាតាទាំងពីរក៏សោយសោក។ ព្រះឥន្ទ្រទ្រង់ប្រាប់ថា: "មាតាទាំងពីរទៅរកអ្នក នឹងត្រលប់មកវិញបន្តិចទៀត..."។ បន្ទាប់មកព្រះឥន្ទ្រក៏ហោះត្រឡប់ទៅវិញ។ ចំណែករាជសីហ៍នាំមាតាទាំងពីរទៅដល់មាត់ជ្រោះក៏ឃើញថ្មបើកឡើង បទុមាយល់ថា: "ស័ង្ខសិល្បជ័យមិនទាន់អស់ព្រះជន្មទេ នេះប្រាកដជាព្រះឥន្ទ្រមកជួយហើយ..."ទើបមាតាទាំងពីរប្រញាប់ឡើងលើរាជសីហ៍ហោះត្រឡប់មកវិញ ហើយក៏បានឃើញបុត្រនៅទីមណ្ឌល។ មាតាទាំងពីរទ្រង់សំណាពេកក្រៃអោបបុត្ររៀបរាប់ថា: "ឱបុត្រថ្លើមថ្លៃចាកចេញពីមាតាទៅយ៉ាងយូរ លុះឮដំណឹងថាបុត្រមរណា មាតាទៅមើលដល់ឃើញថ្មបើកមាតាដឹងថា បុត្រប្រាកដជាបានរួចពីមរណាហើយ"...រួចហើយបទុមាក៏សួរនាំពីដំណើរដែលបុត្របានទៅ។ ស័ង្ខសិល្បជ័យបានរៀបរាប់ប្រាប់មាតាដោយគ្មានចន្លោះឡើយ។

**(សូមរង់ចាំតាមដានរឿងស័ង្ខសិល្បជ័យភាគទី១១ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព